# សមាជិកភាព គណបក្សប្រជាធិបតេយ្យមូលដ្ឋាន

## ក) ប្រភេទសមាជិកភាព សិទ្ធិ កាតព្វកិច្ច របស់សមាជិក

**គ ប ម** មានសមាជិកពីរប្រភេទគឺ សមាជិកជំហរ និងសមាជិកគាំទ្រ ដែលតម្រូវឲ្យមានការដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ និងមានការចេញប័ណ្ណសមាជិកភាព។ ។ **គ ប ម** ក៏ស្វាគមន៍ផងដែរដល់អ្នកមានចំណាប់អារម្មណ៍ទាំងឡាយដែលមានទឹកចិត្តចង់ជួយ **គបម** តាមរយៈការបង់ចវិកាទ្រទ្រង់ស្ម័គ្រចិត្ត ឬការជួយផ្សព្វផ្សាយបន្តអំពីគោលការណ៍ **គ ប ម**។ **គ ប ម** ចាត់ទុកអ្នកទាំងនោះជាអ្នកគាំទ្រទូទៅ។ ពលរដ្ឋកម្ពុជាទាំងអស់ដែលមានអាយុចាប់ពី ១៦ឆ្នាំឡើងទៅអាចចូលជាសមាជិក **គ ប ម** បាន។ សមាជិកផ្តួចផ្តើមបង្កើត **គ ប ម** ដំបូងនៅក្នុងដប់ឃុំ/សង្កាត់គំរូ និងមកពីបណ្តាញសង្គមខ្មែរដើម្បីខ្មែរ ក្លាយជាសមាជិកជំហរជាស្វ័យប្រវត្តិ ចាប់ពីថ្ងៃប្រជុំដំបូងនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៥។ សមាជិកទាំងអស់ត្រូវគោរព និងដើរតាមគោលការណ៍រួមរបស់ **គ ប ម**។

*សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកជំហរ និងសមាជិកគាំទ្រមានដូចតទៅៈ*

| សមាជិកជំហរ | សមាជិកគាំទ្រ |
|---|---|
| *សិទ្ធិ* | *សិទ្ធិ* |
| • បោះឆ្នោតជ្រើសរើសតំណាង | • បោះឆ្នោតជ្រើសរើសតំណាង |
| • ឈរឈ្មោះឲ្យគេបោះឆ្នោត | • ទទួលព័ត៌មានផ្សេងៗ និងផ្តល់យោបល់ |
| • ចូលរួមក្នុងការសម្រេចចិត្តផ្សេងៗរបស់ **គ ប ម** | • ចូលរួមក្នុងការសម្រេចចិត្តផ្សេងៗរបស់ **គ ប ម** នៅមូលដ្ឋាន |
| • ចូលរួមតាមដាន បញ្ចេញមតិយោបល់ និងវាយតម្លៃការងាររបស់ **គ ប ម** | • អាចចូលរួមតាមដានដំណើរការរបស់ **គ ប ម** |
| *កាតព្វកិច្ច* | *កាតព្វកិច្ច* |
| • យល់ដឹង និង ផ្សព្វផ្សាយគោលការណ៍ **គ ប ម** និងជួយស្វែងរកសមាជិកបន្ថែម | • យល់ដឹង និងផ្សព្វផ្សាយគោលការណ៍ **គ ប ម** |
| • បង់ប្រាក់សមាជិកភាព **គ ប ម** ទៀងទាត់ | • បង់ប្រាក់សមាជិកភាព **គ ប ម** ទៀងទាត់ |
| • ចូលរួមប្រជុំ និងសកម្មភាពផ្សេងៗរបស់ **គ ប ម** ដោយទៀងទាត់ | • ចូលរួមប្រជុំ និងសកម្មភាពរបស់ **គ ប ម** ខ្លះៗ |
| • ចូលរួមក្នុងក្រុមសន្សំ | • ចូលរួមក្នុងក្រុមសន្សំដោយស្ម័គ្រចិត្ត |

## ខ) ច្រកសុំចូលជាសមាជិកភាព __គ ប ម__

ដើម្បីចូលជាសមាជិក __គ ប ម__ លោកអ្នកអាចចូលតាមរយៈច្រកបី:

១) តាមឃុំ/សង្កាត់ដែលអ្នករស់នៅ ដែលមានក្រុមការងារ __គ ប ម__ រួចហើយ

២) តាមរយៈការស្គាល់ និងណែនាំពីសមាជិកជំហរណាម្នាក់

៣) តាមរយៈការដឹងឮពីប្រព័ន្ធផ្សព្វផ្សាយ

## គ) នីតិវិធីក្នុងការសុំចូល និងទទួលស្គាល់ជាសមាជិក __គ ប ម__

### *គ.១) សុំចូលតាមឃុំ/សង្កាត់ដែលអ្នករស់នៅ*

- ✓ អ្នកមានចំណាប់អារម្មណ៍តាមឃុំ/សង្កាត់ ដែលមានក្រុមការងាររៀបចំ __គ ប ម__ ឃុំ/សង្កាត់ (មូលដ្ឋាន[1]) រួចហើយ អាចដាក់ពាក្យស្នើសុំចូលជាសមាជិក __គ ប ម__ តាមរយៈសមាជិកក្រុមការងារនៅឃុំ/សង្កាត់ដែលខ្លួនរស់នៅ។
- ✓ ពាក្យស្នើសុំត្រូវបានវាយតម្លៃដោយក្រុមការងារ ឬគណៈកម្មការប្រតិបត្តិ នៅតាមឃុំ/សង្កាត់ យ៉ាងយូរ ១សប្តាហ៍ក្រោយពីទទួលបានពាក្យស្នើសុំ។
- ✓ តំណាងតាមឃុំ/សង្កាត់ ត្រូវផ្ញើឈ្មោះអ្នកអាចក្លាយជាសមាជិក __គ ប ម__ មកអគ្គលេខាធិការដ្ឋានដើម្បីពិនិត្យ និងសម្រេច យ៉ាងយូរ១សប្តាហ៍ក្រោយពីវាយតម្លៃហើយ។
- ✓ ការចេញប័ណ្ណសមាជិកភាពត្រូវធ្វើឡើង និងផ្ញើទៅឃុំ/សង្កាត់វិញយ៉ាងយូរបំផុត១៥ថ្ងៃក្រោយពីទទួលបានឈ្មោះពីតំណាងតាមឃុំ/សង្កាត់។

### *គ.២) សុំចូលតាមរយៈការស្គាល់ និងណែនាំពីសមាជិកជំហរ*

- ✓ អ្នកមានចំណាប់អារម្មណ៍ចូលជាសមាជិក __គ ប ម__ អាចទទួលព័ត៌មាន និងឯកសារអំពី __គ ប ម__ តាមរយៈសមាជិកជំហរណាម្នាក់ ឬស្នើសុំមកអគ្គលេខាធិការដ្ឋាន (ឯកសាររួមមាន ឯកសារគោល ក្រមសីលធម៌សមាជិក និងពាក្យស្នើសុំចូលជាសមាជិក) ឬតាមរយៈគេហទំព័ររបស់ __គបម__ www.gdpcambodia.party ។
- ✓ ក្រោយពីមានការយល់ដឹងអំពីគោលការណ៍របស់ __គ ប ម__ ប្រភេទសមាជិកភាព សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក គាត់ដាក់ពាក្យស្នើសុំចូលជាសមាជិក __គ ប ម__ មកអគ្គលេខាធិការដ្ឋានផ្ទាល់ ឬតាមរយៈអ៊ីម៉ែល ឬគេហទំព័រ __គ ប ម__។
- ✓ ក្រោយពីទទួលពាក្យស្នើសុំ យ៉ាងយូរ១០ថ្ងៃ អគ្គលេខាធិការដ្ឋានត្រូវធ្វើការសម្ភាសន៍ដោយផ្ទាល់មាត់ ឬតាមរយៈទូរស័ព្ទ ឬតាមប្រព័ន្ធអ៊ីម៉ែល ដើម្បីវាយតម្លៃលើពាក្យស្នើសុំ។

---

[1] មូលដ្ឋានសំដៅផងដែរដល់អ្នករស់នៅតំបន់ណាមួយក្នុងទីក្រុង/ទីប្រជុំជននៅប្រទេសកម្ពុជា ឬទីក្រុង/រដ្ឋណាមួយ នៅប្រទេសក្រៅ។

- ✓ ក្រោយពីសម្ភាសន៍ យ៉ាងយូរ៥ថ្ងៃ អគ្គលេខាធិការដ្ឋានត្រូវឆ្លើយតបទៅអ្នកដាក់ពាក្យស្នើសុំ។ ការឆ្លើយតបអាច ១) យល់ព្រម ២) ពន្យាពេលដោយតម្រូវឲ្យបំពេញកិច្ចការបន្ថែម ឬ ៣) បដិសេធជាមួយហេតុផលសមស្រប។
- ✓ ក្រោយពីជូនដំណឹងថាយល់ព្រម ប័ណ្ណសមាជិកភាពត្រូវធ្វើជូន និងផ្តល់ដំណឹងឲ្យមកទទួលក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ។

*គ.៣) សុំចូលតាមរយៈការដឹងឮពីប្រព័ន្ធផ្សព្វផ្សាយ*

- ✓ អ្នកមានចំណាប់អារម្មណ៍ចូលជាសមាជិក **គ ប ម** ក្រោយពីទទួលព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ អាចទទួលព័ត៌មាន និងឯកសារអំពី **គ ប ម** តាមរយៈការស្នើសុំមកអគ្គលេខាធិការដ្ឋាន (ឯកសាររួមមាន ឯកសារគោល ក្រមសីលធម៌សមាជិក និងពាក្យស្នើសុំចូលជាសមាជិក) ឬតាមរយៈគេហទំព័ររបស់ **គ ប ម** www.gdpcambodia.party ។
- ✓ យើងលើកទឹកចិត្តឲ្យអ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមជាសមាជិក **គ ប ម** តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយអំពី **គ ប ម** យ៉ាងតិចឲ្យបានម្តងមុននឹងសម្រេចចិត្តដាក់ពាក្យស្នើសុំចូលជាសមាជិក **គ ប ម** ឬសាកសួរព័ត៌មានអំពីសមាជិកជំហរណាម្នាក់។
- ✓ ក្រោយពីមានការយល់ដឹងអំពីគោលការណ៍របស់ **គ ប ម** ប្រភេទសមាជិកភាព សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក គាត់ដាក់ពាក្យស្នើសុំចូលជាសមាជិក **គ ប ម** មកអគ្គលេខាធិការដ្ឋានផ្ទាល់ ឬតាមរយៈអ៊ីម៉ែល ឬគេហទំព័រ **គ ប ម**។
- ✓ ក្រោយពីទទួលពាក្យស្នើសុំ យ៉ាងយូរ១០ថ្ងៃ អគ្គលេខាធិការដ្ឋានត្រូវធ្វើការសម្ភាសន៍ដោយផ្ទាល់មាត់ ឬតាមរយៈទូរស័ព្ទ ឬតាមប្រព័ន្ធអ៊ីម៉ែល ដើម្បីវាយតម្លៃលើពាក្យស្នើសុំ។
- ✓ ក្រោយពីសម្ភាសន៍ យ៉ាងយូរ៥ថ្ងៃ អគ្គលេខាធិការដ្ឋានត្រូវឆ្លើយតបទៅអ្នកដាក់ពាក្យស្នើសុំ។ ការឆ្លើយតបអាច ១) យល់ព្រម ២) ពន្យាពេលដោយតម្រូវឲ្យបំពេញកិច្ចការបន្ថែម ឬ ៣) បដិសេធជាមួយហេតុផលសមស្រប។
- ✓ ក្រោយពីជូនដំណឹងថាយល់ព្រម ប័ណ្ណសមាជិកភាពត្រូវធ្វើជូន និងផ្តល់ដំណឹងឲ្យមកទទួលក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ។

**ឃ) ការដកសិទ្ធិ និងការបាត់បង់សមាជិកភាព គ ប ម**

សិទ្ធិរបស់សមាជិកជំហរ ឬ សមាជិកគាំទ្រដែលមានចែងក្នុង[ឧបសម្ព័ន្ធ២] អាចត្រូវបានដកចេញក្នុងករណីសមាជិកណាម្នាក់មិនបានបំពេញកាតព្វកិច្ចបានត្រឹមត្រូវ។ ការខកខានបង់ប្រាក់សមាជិកភាពទៀងទាត់ ឬការមិនចូលរួមសកម្មភាពរបស់ **គ ប ម** ច្រើនលើក (លើស ៥០% នៃសកម្មភាពប្រចាំឆ្នាំ) ជាមូលហេតុដ៏ចំបងមួយក្នុងការដកសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត ឬសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន។ គណៈកម្មការប្រតិបត្តិគ្រប់កំរិត មានសិទ្ធិសម្រេចដកសិទ្ធិណាមួយរបស់សមាជិកណាម្នាក់។ ក្នុងករណីមិនសុខចិត្តចំពោះការសម្រេចដកសិទ្ធិ សមាជិកនោះអាចប្ដឹងទៅគណៈកម្មាធិការវិន័យ និងដោះស្រាយវិវាទ។

សមាជិកណាម្នាក់អាចនឹងត្រូវបាត់សមាជិកភាព ក្នុងករណីរំលោភធ្ងន់ធ្ងរដល់គោលការណ៍រួមរបស់ **គ ប ម**។ ករណីរំលោភធ្ងន់ធ្ងរដល់គោលការណ៍រួម មានដូចជាការលួចបន្លំទ្រព្យសម្បត្តិ **គ ប ម** បង្ខូចកេរ្តិ៍ឈ្មោះ **គ ប ម** តាមប្រព័ន្ធសារព័ត៌មាន រំលោភបំពានលើអ្នកដទៃដោយជាក់ស្ដែង។ល។ គណៈកម្មការប្រតិបត្តិគ្រប់កំរិតអាចស្នើសុំបញ្ឈប់សមាជិកភាពរបស់សមាជិកណាម្នាក់ទៅគណៈកម្មាធិការដោះស្រាយវិវាទ និងវិន័យ ដែលមានសិទ្ធិសម្រេចចុងក្រោយក្នុងការបញ្ឈប់សមាជិកភាពរបស់សមាជិកណាម្នាក់។

## ង) ប្រាក់សមាជិកភាព

គណៈកម្មការបណ្ដោះអាសន្នបានសម្រេចក្នុងអង្គប្រជុំថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៥ កំណត់ប្រាក់សមាជិកភាពអប្បបរិមាដូចតទៅ៖

| **ស្ថានភាពចំណូល** | **កំរិតប្រាក់សមាជិកភាពក្នុង១ខែ** |
|---|---|
| ចំណូលតិចតួច | ២.០០០ រៀល |
| ចំណូលមធ្យម | ១០.០០០ រៀល |
| ចំណូលខ្ពស់ | ៤០.០០០ រៀល |

*កំណត់សំគាល់:*

- ✓ សមាជិកម្នាក់ៗកំណត់ស្ថានភាពចំណូលដោយខ្លួនឯងដោយស្មោះត្រង់។
- ✓ ប្រាក់សមាជិកភាពអាចបង់ជាប្រចាំឆ្នាំក៏បាន។

*ឧបសម្ព័ន្ធ១*: **ពាក្យសុំចូលជាសមាជិក គ ប ម**

ខ្ញុំឈ្មោះ ………………………………… អក្សរឡាតាំង: ………………………………

រូបថត ៤X៦

អនុម័តដោយគណៈកម្មការបណ្ដោះអ

ថ្ងៃខែឆ្នាំកំណើត: ........./............../..............          ភេទ:  .......

ទីកន្លែងកំណើត: ភូមិ ................ ឃុំ/សង្កាត់ ......................ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង......................

ទីលំនៅបច្ចុប្បន្ន: ភូមិ ..............ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ ........................ខេត្ត/ក្រុង.........................

ស្ថានភាពគ្រួសារ[2]............. កម្រិតវប្បធម៌ .................................. អត្តសញ្ញាណប័ណ្ណលេខ.........................

លេខទូរស័ព្ទ................................. អ៊ីម៉ែល.........................................

ត្រូវបានណែនាំឲ្យចូលជាសមាជិកតាមរយៈ ឈ្មោះ...........................................ឬតាមប្រព័ន្ធផ្សព្វផ្សាយ ☐

សុំចូលជា      សមាជិកជំហរ ☐      សមាជិកគាំទ្រ ☐      របស់គណបក្សប្រជាធិបតេយ្យមូលដ្ឋាន

ខ្ញុំបានអាន និងយល់ដឹងអំពីឯកសារគោល **គ ប ម** ក្រមសីលធម៌សមាជិក សិទ្ធិ និងកាតព្វកិច្ចសមាជិក របស់ **គ ប ម**។ ខ្ញុំប្តេជ្ញាចិត្តគោរព ដើរតាមគោលការណ៍រួម និងបំពេញកាតព្វកិច្ចជាសមាជិករបស់ **គ ប ម**។

ទីកន្លែងទទួលពាក្យ............................................. កាលបរិច្ឆេទទទួលពាក្យ..................................

អ្នកសុំចុះឈ្មោះ                    អ្នកទទួល

ហត្ថលេខា                    ហត្ថលេខា

**សម្គាល់:**

- ✓ ប័ណ្ណសមាជិកភាពនឹងត្រូវផ្តល់ជូនក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរក្រោយពីការវាយតម្លៃលើពាក្យស្នើសុំ។
- ✓ បេក្ខជនត្រូវភ្ជាប់មកជាមួយនូវរូបថត ៣x៤ មួយសន្លឹក និង ប្រាក់ ១០០០រៀលសម្រាប់ថ្លៃប័ណ្ណសមាជិក។

## *ឧបសម្ព័ន្ធ២*: **សិទ្ធិ និងកាតព្វកិច្ចរបស់ សមាជិកជំហរ និងសមាជិកគាំទ្រ**

[2] នៅលីវ រៀបការរួច មេម៉ាយ ពោះម៉ាយ

| សមាជិកជំហរ | សមាជិកគាំទ្រ |
|---|---|
| *សិទ្ធិ* | *សិទ្ធិ* |
| • បោះឆ្នោតជ្រើសរើសតំណាង | • បោះឆ្នោតជ្រើសរើសតំណាង |
| • ឈរឈ្មោះឲ្យគេបោះឆ្នោត | • ទទួលព័ត៌មានផ្សេងៗ និងផ្តល់យោបល់ |
| • ចូលរួមក្នុងការសម្រេចចិត្តផ្សេងៗរបស់ **<u>គ ប ម</u>** | • ចូលរួមក្នុងការសម្រេចចិត្តផ្សេងៗរបស់ **<u>គ ប ម</u>** នៅមូលដ្ឋាន |
| • ចូលរួមតាមដាន បញ្ចេញមតិយោបល់ និងវាយតម្លៃការងាររបស់ **<u>គ ប ម</u>** | • អាចចូលរួមតាមដានដំណើរការរបស់ **<u>គ ប ម</u>** |
| *កាតព្វកិច្ច* | *កាតព្វកិច្ច* |
| • យល់ដឹង និង ផ្សព្វផ្សាយគោលការណ៍ **<u>គ ប ម</u>** និងជួយស្វែងរកសមាជិកបន្ថែម | • យល់ដឹង និងផ្សព្វផ្សាយគោលការណ៍ **<u>គ ប ម</u>** |
| • បង់ប្រាក់សមាជិកភាព **<u>គ ប ម</u>** ទៀងទាត់ | • បង់ប្រាក់សមាជិកភាព **<u>គ ប ម</u>** ទៀងទាត់ |
| • ចូលរួមប្រជុំ និងសកម្មភាពផ្សេងៗរបស់ **<u>គ ប ម</u>** ដោយទៀងទាត់ | • ចូលរួមប្រជុំ និងសកម្មភាពរបស់ **<u>គ ប ម</u>** ខ្លះៗ |
| • ចូលរួមក្នុងក្រុមសន្សំ | • ចូលរួមក្នុងក្រុមសន្សំដោយស្ម័គ្រចិត្ត |

## ឧបសម្ព័ន្ធ៣: **ក្រមសីលធម៌សមាជិក សមាជិកា គណបក្សប្រជាធិបតេយ្យមូលដ្ឋាន**

ដើម្បីចូលរួមចំណែកក្នុងវិស័យនយោបាយ និងសង្គមឲ្យមានប្រសិទ្ធភាព ក្នុងគោលបំណងដោះស្រាយបញ្ហាជាតិ និងសង្គមប្រកបដោយគតិបណ្ឌិតក្នុងស្មារតី "សាមគ្គីភាព យុត្តិធម៌ អហិង្សា" ក៏ដូចជាពង្រឹងលទ្ធិប្រជាធិបតេយ្យ និងលើកកំពស់សីលធម៌សង្គម សមាជិក សមាជិកា **<u>គ ប ម</u>** ទាំងអស់ត្រូវគោរពក្រមសីលធម៌ដូចតទៅៈ

១) គោរពគុណតំលៃ និងគោលការណ៍របស់ **<u>គ ប ម</u>**។

២) ធ្វើតែអំពើល្អ (កាយ វាចា ចិត្ត) ផ្តល់ភាពជាគំរូល្អ ក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម។

៣) មិនប្រព្រឹត្តអំពើពុករលួយ បក្សពួក និងគ្រួសារនិយម ដោយតម្កល់ផលប្រយោជន៍សាធារណៈ និងជាតិជាធំ។

៤) មិនប្រើភាសាជេរប្រមាថ ម៉ាក់ងាយ និងលាបពណ៌ ជាពិសេសចំពោះអ្នកមិនគាំទ្រ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន។ ផ្តល់ការរិៈគន់បែបស្ថាបនាលើបញ្ហាប្រឈមផ្សេងៗ។

៥) ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។

៦) យល់ទុក្ខធុរៈ និងចេះជួយអ្នកទន់ខ្សោយ និងអ្នកងាយរងគ្រោះ។

៧) ឧស្សាហ៍ព្យាយាម សន្សំសំចៃ ម៉ឺងមាត់ម៉ត់ចត់។

៨) ខិតខំរៀនសូត្របង្កើនសមត្ថភាពរបស់ខ្លួនជានិច្ច ដើម្បីជួយគ្រួសារ សហគមន៍ និងជាតិ។

សមាជិក សមាជិកា ដែលគោរព និងអនុវត្តក្រមសីលធម៌បានល្អ នឹងទទួលបានការសរសើរលើកទឹកចិត្ត ដោយឡែកសមាជិក សមាជិកា ណាម្នាក់ជាពិសេសសមាជិក សមាជិកាក្នុងរចនាសម្ព័ន្ធដឹកនាំគ្រប់កំរិត និងសមាជិកជំហរដែលមិនគោរពក្រមសីលធម៌ដូចមានចែងខាងលើ អាចនឹងត្រូវទទួលការដាក់ពិន័យពី **<u>គ ប ម</u>**។

*ឧបសម្ព័ន្ធ៤*: **ឯកសារគោល <u>គ ប ម</u>**

## ឯកសារគោល

### "ការបង្កើតគណបក្សប្រជាធិបតេយ្យមូលដ្ឋាន"

### *"ជម្រើសថ្មីសម្រាប់កម្ពុជា"*

***១-ឈ្មោះគណបក្ស:*** «គណបក្សប្រជាធិបតេយ្យមូលដ្ឋាន» ដែលមានអក្សរកាត់ **<u>គ ប ម</u>**។

***២-រូបសញ្ញាគណបក្ស:*** ត្រីកោណ (សមង្ស) តំណាងឲ្យប្រជាធិបតេយ្យពីក្រោមមកលើ យកមូលដ្ឋានជាធំ ដែលមានផ្ទៃខាងក្នុងពណ៌បៃតង ជ្រុងបាតពណ៌ក្រហម ជ្រុងទាំងសងខាងពណ៌ខៀវ និងអក្សរ «**គ ប ម**» ពណ៌សនៅចំកណ្តាលផ្ទៃទាំងមូល។

***៣-គុណតម្លៃ:*** «សាមគ្គីភាព យុត្តិធម៌ អហិង្សា»។

***៤-ទស្សនវិស័យ*** *(គោលបំណងវែងឆ្ងាយ):*

"ប្រជាពលរដ្ឋរស់នៅមានជីវិតថ្លៃថ្នូរ និងប្រទេសជាតិមានអធិបតេយ្យពេញលេញ"។

***៥-បេសកកម្ម:*** "បណ្តុះអ្នកដឹកនាំល្អ និងកសាងមូលដ្ឋានគ្រឹះប្រជាធិបតេយ្យទូទាំងប្រទេស"។

***៦-គោលការណ៍គ្រឹះ***

១-ស្ម័គ្រចិត្ត និងបើកចំហ

២-សមាជិកធិបតេយ្យ (ប្រជាធិបតេយ្យផ្ទៃក្នុងបក្ស)

៣-ប្រជាធិបតេយ្យបែបរិមជ្ឈការ

៤-អ្នកដឹកនាំខាងលើដើរតួនាទីជាអ្នកសម្របសម្រួល និងពង្រឹងសមត្ថភាពសមាជិក និងប្រជាពលរដ្ឋទូទៅ

៥-ភាពជាម្ចាស់ ជាពិសេសស្វ័យភាពហិរញ្ញវត្ថុ។

***៧-គោលការណ៍សំខាន់ៗក្នុងការរៀបចំរចនាសម្ព័ន្ធដឹកនាំរបស់ គ ប ម***

១-សមាជជាអង្គការកំពូលរបស់ **<u>គ ប ម</u>** (សមាជមូលដ្ឋាន និងថ្នាក់ជាតិ) ដែលមានសមាជិកជាប្រតិភូតំណាងដែលជ្រើសតាំងតាមរយៈការបោះឆ្នោត។

២-រាល់សមាជិកក្នុងរចនាសម្ព័ន្ធដឹកនាំថ្នាក់ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/រាជធានី និងជាតិត្រូវជ្រើសតាំងពីក្រោមមកលើ តាមរយៈការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ តាមរយៈសមាជ។ ញាតិលោហិត និងញាតិពន្ធទី១ (ប្តី ប្រពន្ធ កូន បងប្អូនឪពុកម្តាយ បង្កើត ក្មេក និងសាច់

ថ្លៃ) ត្រូវហាមឃាត់នៅក្នុងសមាសភាពថ្នាក់ដឹកនាំចាប់ពីថ្នាក់ឃុំដល់ជាតិ (ក្នុងអង្គភាពគ្រប់គ្រងតែមួយ)។ សមាជិកដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធថ្នាក់ដឹកនាំនឹងអាចត្រូវបានបោះឆ្នោតដកចេញពីតួនាទីក្នុងចន្លោះអាណត្តិក្នុងករណីចាំបាច់។

៣-បេក្ខជនក្រុមប្រឹក្សាឃុំ/សង្កាត់ តំណាងរាស្ត្រគ្រប់ខេត្ត និងរាជធានី ត្រូវជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដោយសមាជិកជំហរនៅតាមឃុំ/សង្កាត់ ខេត្ត និងរាជធានីនីមួយៗ។

៤-បេក្ខជននាយករដ្ឋមន្ត្រីត្រូវបានបោះឆ្នោតជ្រើសតាំងដោយសមាជថ្នាក់ជាតិ។

៥-រាល់សមាជិកក្នុងរចនាសម្ព័ន្ធដឹកនាំ ចាប់ពីថ្នាក់ឃុំដល់ថ្នាក់ជាតិ ត្រូវប្រកាសទ្រព្យសម្បត្តិដោយចំហ នៅពេលទទួលតួនាទីក្នុងអង្គការចាត់តាំងរដ្ឋ។

### *៨-លក្ខណៈសម្បត្តិសមាជិកជំហរ*

១-មានសីលធម៌ល្អ ស្មោះត្រង់ គោរពគុណតម្លៃ និងគោលការណ៍របស់ **គ ប ម**

២-មានសមត្ថភាពយល់ដឹង និងចេះដោះស្រាយបញ្ហាមូលដ្ឋានបានល្អ

៣-មានមនសិការជាតិ គិតផលប្រយោជន៍រួម និង

៤-មានអ្នកគាំទ្រចាប់ពី ១០នាក់ឡើងទៅ។

### *៩-គោលការណ៍ហិរញ្ញវត្ថុ*

#### *ក. ប្រភពថវិកាសម្រាប់ទ្រទ្រង់ គ ប ម*

១-វិភាគទានសមាជិកភាពរបស់សមាជិកជំហរ

២-ចំណូលពីការប្រាក់របស់ក្រុមសន្សំ និងការវិនិយោគផ្សេងៗ

៣-វិភាគទានស្ម័គ្រចិត្តរបស់សមាជិកគាំទ្រ និង

៤-ចំណូលស្របច្បាប់ផ្សេងៗ។

#### *ខ. គោលការណ៍ និងការគ្រប់គ្រងចំណូល-ចំណាយ*

១. តម្លាភាព និងគណនេយ្យភាព

២. មានគំរោងផែនការថវិកា និងខ្ទង់ចំណាយច្បាស់លាស់

៣. គោរពតាមគោលការណ៍ប្រតិបត្តិហិរញ្ញវត្ថុរបស់ **គ ប ម**។